# ព្រះរាជក្រម

នស/រកម/០៨១៦/០១៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

## ស្តីពី

# ការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងតម្លាភាពក្នុងការព្យាបាលសង្គ្រោះជីវិត និងបង្កើនសុខុមាលភាពរបស់ប្រជាពលរដ្ឋតាមរយៈការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងធានាការពារទប់ស្កាត់ការជួញដូរកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីក្នុងការគ្រប់គ្រងការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្សប្រកបដោយសុវត្ថិភាព និងស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពដែលពាក់ព័ន្ធនឹងអ្នកបរិច្ចាគមានជីវិត ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ ៖

- **មន្ទីរពេទ្យ** សំដៅដល់មន្ទីរពេទ្យសាធារណៈ និងឯកជន ដែលបានចុះបញ្ជី និងប្រកាសទទួលស្គាល់ដោយក្រសួងសុខាភិបាលជាមន្ទីរពេទ្យដែលមានគុណវុឌ្ឍិក្នុងការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស ។
- **អ្នកប្រកបវិជ្ជាជីវៈ** សំដៅដល់អ្នកមានវិជ្ជាជីវៈទាំងឡាយណាដែលបានចុះបញ្ជីក្នុងគណៈវិជ្ជាជីវៈសុខាភិបាល និងគណៈវិជ្ជាជីវៈពាក់ព័ន្ធ និងមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈត្រឹមត្រូវ ។
- **កោសិកា** សំដៅដល់ឯកតាដ៏តូចបំផុតនៃសារពាង្គកាយរស់ ដែលអាចយកទៅផ្សាំ ហើយអាចបំពេញមុខងារបាន ។
- **ជាលិកា** សំដៅដល់បណ្តុំនៃកោសិកាជាច្រើន ហើយបណ្តុំនៃជាលិកានេះបង្កើតជាផ្នែកណាមួយនៃសារពាង្គកាយរស់ ។
- **សរីរាង្គ** សំដៅដល់ផ្នែកទាំងមូល ឬបំណែកសំខាន់ណាមួយនៃសារពាង្គកាយមនុស្ស ដែលកើតចេញមកពីបណ្តុំជាលិកា និងបណ្តាញសរសៃឈាមស្រោចស្រព ហើយអាចបំពេញមុខងារសរីរសាស្ត្រ ក្នុងកម្រិតស្វយ័តណាមួយ ។

- ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស សំដៅដល់ដំណើរការនៃការដកយក ការដាក់ចូល ការរក្សាទុក ការដឹកជញ្ជូន ការផ្គូរផ្គងកោសិកា ជាលិកា ឬសរីរាង្គមនុស្ស តាមលក្ខណៈបច្ចេកទេសវេជ្ជសាស្ត្រត្រឹមត្រូវ ។
- ការធ្វើពាណិជ្ជកម្ម សំដៅដល់ទម្រង់នៃការជួញដូរកោសិកា ជាលិកា ឬសរីរាង្គមនុស្សដើម្បីកេងចំណេញផលប្រយោជន៍ផ្ទាល់ខ្លួន ។

# ជំពូកទី ២

# សមត្ថកិច្ចគ្រប់គ្រង

## មាត្រា ៥.-

ក្រសួងសុខាភិបាល ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងផ្តល់ការអនុញ្ញាតដល់មន្ទីរពេទ្យ និងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលក្នុងការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ។

ក្រសួងសុខាភិបាលត្រូវបង្កើតគណៈកម្មាធិការមួយដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងអនុញ្ញាតដល់មន្ទីរពេទ្យ និងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលក្នុងការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

# ជំពូកទី ៣

# ការបរិច្ចាគ និងការទទួលសរីរាង្គមនុស្ស

## ផ្នែកទី ១

## គោលការណ៍ទូទៅ

## មាត្រា ៦.-

ការបរិច្ចាគ និងការទទួលសរីរាង្គមនុស្សត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម ៖

- តាមការស្ម័គ្រចិត្តពីអ្នកបរិច្ចាគ និងអ្នកទទួល ឬគោលបំណងសប្បុរសធម៌ និងមនុស្សធម៌
- មិនធ្វើពាណិជ្ជកម្ម និងមិនមានការផ្សាយពាណិជ្ជកម្ម
- សុវត្ថិភាពសុខភាពរបស់អ្នកបរិច្ចាគ និងអ្នកទទួល និង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

- រក្សាការសម្ងាត់របស់អ្នកបរិច្ចាគ និងអ្នកទទួល លើកលែងតែមានការឯកភាពគ្នាពីភាគីពាក់ព័ន្ធ ឬកំណត់ដោយច្បាប់ជាធរមាន ។

## ផ្នែកទី ២
## អ្នកបរិច្ចាគ

### មាត្រា ៧.-

អ្នកបរិច្ចាគ ត្រូវមានអាយុយ៉ាងតិច ១៨ ឆ្នាំ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ហើយវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ។

ចំពោះជនវិកលចរិត ឬជនវិបល្លាសស្មារតី ការបរិច្ចាគកោសិកា ជាលិកា និងសរីរាង្គត្រូវហាមឃាត់ ទោះជាមានការយល់ព្រមពីឪពុកម្ដាយ ឬអ្នកអាណាព្យាបាលក៏ដោយ ។

### មាត្រា ៨.-

អ្នកបរិច្ចាគមានសិទ្ធិ ឬអនុញ្ញាតឲ្យមានការដកចេញនូវកោសិកា ជាលិកា និងសរីរាង្គណាមួយរបស់ខ្លួនតាមរយៈការបរិច្ចាគដោយស្ម័គ្រចិត្តក្នុងគោលបំណងព្យាបាលជំងឺ និងមិនធ្វើពាណិជ្ជកម្ម ។

### មាត្រា ៩.-

អ្នកបរិច្ចាគ និងអ្នកទទួលត្រូវព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ ការព្រមព្រៀងគ្នាជាលាយ-លក្ខណ៍អក្សរត្រូវធ្វើនៅចំពោះមុខគណៈកម្មការសម្រាប់ផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ។ ប្រសិនបើអ្នកបរិច្ចាគ ឬអ្នកទទួលមិនចេះអក្សរ ការព្រមព្រៀងត្រូវសរសេរឲ្យច្បាស់លាស់ក្នុងកំណត់ហេតុថាអ្នកព្រមព្រៀងមិនចេះអក្សរយល់ព្រមជាមួយគ្នា ដើម្បីឲ្យមន្ទីរពេទ្យធ្វើការវះកាត់ និងផ្លាស់ប្ដូរនូវសរីរាង្គរបស់ខ្លួន ។

### មាត្រា ១០.-

អ្នកបរិច្ចាគត្រូវទទួលបាននូវការថែទាំសុខភាព សុខុមាលភាពមុនពេល ក្នុងកំឡុងពេល និងក្រោយពេលបរិច្ចាគ ពីមន្ទីរពេទ្យដែលធ្វើការផ្សាំកោសិកា ជាលិកា និងសរីរាង្គ ។

រាល់ការចំណាយលើការថែទាំសុខភាព សុខុមាលភាពដែលទាក់ទងនឹងការផ្សាំកោសិកា ជាលិកា និងសរីរាង្គមុនពេល ក្នុងកំឡុងពេល និងក្រោយពេលបរិច្ចាគជាបន្ទុករបស់មន្ទីរពេទ្យដែលធ្វើការផ្សាំកោសិកា ជាលិកា និងសរីរាង្គ ។

## ផ្នែកទី ៣
## អ្នកទទួល

**មាត្រា ១១.-**

អ្នកទទួលដែលរង់ចាំការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គរបស់បុគ្គលណាម្នាក់ដែលមិនបានព្រមព្រៀងគ្នាជាមុន ត្រូវចុះឈ្មោះក្នុងបញ្ជីរង់ចាំ ។

បែបបទ និងនីតិវិធីបញ្ជីរង់ចាំនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ផ្នែកទី៤
## ករណីយកិច្ចរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល

**មាត្រា ១២.-**

អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលរបស់មន្ទីរពេទ្យ ត្រូវពន្យល់អំពីដំណើរការនៃការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងរាល់ផលប៉ះពាល់ ឬផលវិបាក ឬគ្រោះថ្នាក់ដែលអាចកើតមានឡើងដល់អ្នកបរិច្ចាគមុននឹងសុំការយល់ព្រម ។

អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលរបស់មន្ទីរពេទ្យ ត្រូវធានាឲ្យបានថាអ្នកដែលផ្តល់ការយល់ព្រមបរិច្ចាគពិតជាបានយល់ និងមានសមត្ថភាពសតិបញ្ញាពេញលេញក្នុងការធ្វើសេចក្តីសម្រេចចិត្តបរិច្ចាគ ។

**មាត្រា ១៣.-**

អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ដែលបានអនុញ្ញាតដោយក្រសួងសុខាភិបាលឲ្យធ្វើការងារទាក់ទងនឹងការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្សត្រូវពន្យល់អំពីដំណើរការនៃការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងរាល់គុណប្រយោជន៍ ផលប៉ះពាល់ ផលវិបាក ឬគ្រោះថ្នាក់ដែលអាចមានទាក់ទងនឹងការផ្សាំ មុននឹងមានការយល់ព្រមពីអ្នកទទួល ។

**មាត្រា ១៤.-**

រាល់ការសុំការយល់ព្រមក្នុងការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរចំនួន ២ (ពីរ) ច្បាប់ ដែលត្រូវរក្សាទុកនៅមន្ទីរពេទ្យដែលធ្វើការផ្សាំកោសិកា ជាលិកា ឬសរីរាង្គ ១ (មួយ) ច្បាប់ និងក្រសួងសុខាភិបាល ១ (មួយ) ច្បាប់ ។

**មាត្រា ១៥.-**

បន្ទាប់ពីដកកោសិកា ជាលិកា ឬសរីរាង្គមនុស្សចេញពីរាងកាយរបស់មនុស្ស អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលរបស់មន្ទីរពេទ្យត្រូវចាត់វិធានការរក្សាកោសិកា ជាលិកា ឬសរីរាង្គមនុស្សដែលបានដកចេញនោះដោយគោរពតាមគោលការណ៍បច្ចេកទេសដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

ROYAUME DU CAMBODGE · MINISTÈRE DU PALAIS ROYAL

## ផ្នែកទី ៥
## ករណីយកិច្ចរបស់មន្ទីរពេទ្យ

**មាត្រា ១៦.-**

មន្ទីរពេទ្យ ត្រូវទទួលខុសត្រូវរៀបចំបង្កើតគណៈកម្មការសម្រាប់ការងារផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្សដើម្បី ៖

-វាយតម្លៃអំពីសមត្ថភាព និងលទ្ធភាពបរិច្ចាគរបស់អ្នកដែលមានសក្តានុពលក្នុងការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គ

- តាមដាន និងឃ្លាំមើលការវិវត្តទៅរកភាពជាសះស្បើយក្រោយពេលវះកាត់ដកកោសិកា ជាលិកា ឬសរីរាង្គរហូតដល់ពេលអ្នកបរិច្ចាគមានស្ថានភាពសុខភាពធម្មតា

- ផ្តល់ការថែទាំ ព្យាបាល និងតាមដានបញ្ហាសុខភាពដែលពាក់ព័ន្ធនឹងការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គ ។

តួនាទី និងភារកិច្ចរបស់គណៈកម្មការសម្រាប់ការងារផ្សាំកោសិកា ជាលិកា សរីរាង្គនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ១៧.-**

ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស មិនត្រូវបានអនុញ្ញាតឲ្យធ្វើឡើងក្នុងគោលបំណងធ្វើពាណិជ្ជកម្មឡើយ ។

ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មទាក់ទងទៅនឹងការទិញលក់សរីរាង្គមនុស្ស ត្រូវហាមឃាត់ជាដាច់ខាត ។

## ផ្នែកទី ៦
## ករណីយកិច្ចរបស់ក្រសួងសុខាភិបាល

**មាត្រា ១៨.-**

ក្រសួងសុខាភិបាលត្រូវធ្វើប្រតិបត្តិការត្រួតពិនិត្យរាល់សកម្មភាពដែលពាក់ព័ន្ធ ទៅលើការផ្សាំកោសិកា ជាលិកា ឬសរីរាង្គ ។

សិទ្ធិ និងតួនាទីភារកិច្ចរបស់ភាគីដែលពាក់ព័ន្ធនឹងការផ្សាំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ១៩.-**

មន្ទីរពេទ្យ និងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលក្នុងការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ត្រូវសុំការអនុញ្ញាតពីក្រសួងសុខាភិបាល ។

បែបបទ និងលក្ខខណ្ឌនៃការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៤

## ទោសប្បញ្ញត្តិ

**មាត្រា ២០.-**

អំពើប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ក្នុងការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២១.-**

អំពើដកយកកោសិកា ជាលិកា ឬសរីរាង្គមនុស្សពីជនដែលត្រូវបានហាមឃាត់ការបរិច្ចាគ ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើខាងលើនេះ នាំឲ្យមានការកាត់អវយវៈ ឬនាំឲ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ឬបណ្តាលឲ្យជនរងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ២២.-**

អំពើដកយកកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ដោយគ្មានការបង្ហាញឆន្ទៈយល់ព្រមបរិច្ចាគពីអ្នកបរិច្ចាគ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដូចកថាខណ្ឌទី ១ ខាងលើ ចំពោះអំពើអូសទាញ លួងលោម បោកបញ្ឆោត ឬប្រើឧបាយកលទុច្ចរិតផ្សេងទៀត ដើម្បីទទួលបានការយល់ព្រមបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គមនុស្សពីអ្នកបរិច្ចាគ ។

ត្រូវចាត់ទុកថាគ្មានការយល់ព្រមពីអ្នកបរិច្ចាគ ចំពោះករណីដែលការព្រមព្រៀងរវាងអ្នកបរិច្ចាគ និងអ្នកទទួល មិនបានធ្វើជាលាយលក្ខណ៍អក្សរ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើខាងលើនេះ នាំឲ្យមានការកាត់អវយវៈ ឬនាំឲ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ឬបណ្តាលឲ្យជនរងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់ ។

## មាត្រា ២៣.-

អំពើផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ក្នុងគោលបំណងពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ។

## មាត្រា ២៤.-

អំពើផ្សព្វផ្សាយពាណិជ្ជកម្មទាក់ទងនឹងការទិញលក់សរីរាង្គមនុស្ស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

## មាត្រា ២៥.-

អំពើបំពានកាតព្វកិច្ចដូចបានកំណត់ក្នុងមាត្រា ១០ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន)រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

## មាត្រា ២៦.-

អំពើមិនផ្តល់ព័ត៌មានអំពីដំណើរការនៃការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងផលប៉ះពាល់ ឬផលវិបាក ឬគ្រោះថ្នាក់ដែលអាចកើតមានឡើងដល់អ្នកបរិច្ចាគ មុននឹងសុំការយល់ព្រម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

## មាត្រា ២៧.-

អំពើមិនផ្តល់ព័ត៌មានអំពីដំណើរការនៃការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងរាល់គុណប្រយោជន៍ ផលប៉ះពាល់ ផលវិបាក ឬគ្រោះថ្នាក់ ដែលអាចកើតមានដល់អ្នកទទួល មុននឹងមានការយល់ព្រមពីអ្នកទទួល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

## មាត្រា ២៨.-

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចមានចែងក្នុងមាត្រា ២០៦ (ទោសបន្ថែម : ប្រភេទ និងរយៈពេល) នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាសចំពោះរូបវន្តបុគ្គល ។

**មាត្រា ២៩.-**

ចំពោះបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចមានចែងក្នុងមាត្រា ២០៨ (ទោសបន្ថែម : ប្រភេទ និងរយៈពេល) នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាសចំពោះរូបវន្តបុគ្គល ។

**មាត្រា ៣០.-**

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៤ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២-ការដាក់ឲ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមព្រហ្មទណ្ឌ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមព្រហ្មទណ្ឌ ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៣១.-**

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២០ មាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២-ការដាក់ឲ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមព្រហ្មទណ្ឌ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមព្រហ្មទណ្ឌ ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ៣២.-**

ការគ្រប់គ្រងឈាម មេជីវិត ខួរឆ្អឹង និងកោសិកាដើមរបស់មនុស្ស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៣៣.-**

បទប្បញ្ញត្តិទាក់ទងនឹងការនាំចេញកោសិកា ជាលិកា សរីរាង្គមនុស្ស ទៅក្រៅប្រទេស ឬនាំចូលកោសិកា ជាលិកា សរីរាង្គមនុស្ស មកក្នុងប្រទេសកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ៣៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ពរល.១៦០៨.៧៦៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ហត្ថលេខា**

**ម៉ម ប៊ុនហេង**

លេខ: ៧៥៤ ស.ណ

សំណៅចម្លងត្រឹមត្រូវតាមច្បាប់ដើមសម្រាប់ការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១[illegible] ខែ [illegible]ា ឆ្នាំ២០១៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

សយ សុខា